ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៦ លេខ ៥

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC




ក ស វ

# Work Activities

ប្រចាំខែឧសភា ឆ្នាំ២០១៣



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ការប្រើភាសានិងអក្សរខ្មែរនៅលើរូបសញ្ញា | ១ |
| ២- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវលំ | ២ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមីនា ឆ្នាំ២០១៣ | ៤ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១១ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការកំណត់ការប្រើភាសានិងអក្សរខ្មែរនៅលើរូបសញ្ញា

បន្ទាប់ពីបញ្ចប់កិច្ចប្រជុំជំនាញបច្ចេកទេស សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ការប្រើភាសា និងអក្សរខ្មែរនៅលើរូបសញ្ញាត្រូវបានដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងបន្តទៀត។ ដំណើរការកិច្ចប្រជុំអន្តរក្រសួងបានបញ្ចប់នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣។

សាវតារនៃការរៀបចំសេចក្តីព្រាង គឺវិទ្យាស្ថានភាសាជាតិរាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំសន្និសីទជាតិជាច្រើនលើក នៅឆ្នាំ២០០០ ឆ្នាំ២០០៥ និងឆ្នាំ២០០៦ ដើម្បីស្វែងយល់រកយន្តការសម្រាប់ធ្វើឲ្យមានការឯកភាពគ្នាក្នុងភាសាខ្មែរ។ ក្នុងសន្និសីទ រាល់សមាជិក-សមាជិកា បានផ្តល់ជាអនុសាសន៍សំខាន់ៗជាច្រើន ក្នុងនោះតែងតែមានការសុំឲ្យបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ និងសុំឲ្យប្រើអក្ខរាវិរុទ្ធនៃភាសាខ្មែរ តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត**។ ហេតុនេះ ទើបនៅឆ្នាំ២០០៧ គណៈកម្មាធិការជាតិភាសាខ្មែរ(គ.ជ.ភ.ខ.) ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ១៨ អនក្រ.បក ដែលមានភារកិច្ចរកការឯកភាពក្នុងការសរសេរ ការអាន ការបង្កើតពាក្យ និងកម្ចីពាក្យពីភាសាបរទេស។ មិនយូរប៉ុន្មាននៅឆ្នាំ២០០៨ គ.ជ.ភ.ខ. បានអនុម័តជាឯកច្ឆ័ន្ទយកវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាមូលដ្ឋានក្នុងការសរសេរនិងការអានពាក្យនៃភាសាខ្មែរ។

ដោយការងាររបស់ គ.ជ.ភ.ខ. មានទំហំធំឡើងៗក្នុងការរកឯកភាពជូនភាសាជាតិ រាជរដ្ឋាភិបាលបានផ្តល់កិត្តិយសដល់ គ.ជ.ភ.ខ. នេះ ដោយដំឡើងឲ្យទៅជា ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)វិញ តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ឆ្នាំ២០១១ និងមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការដែលមានផ្នែកចំណុះចំនួន៣។

នៅស្របពេលជាមួយគ្នាដែលព្រះរាជក្រឹត្យស្តីពីការបង្កើត ក.ជ.ភ.ខ. និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ ក.ជ.ភ.ខ. កំពុងនៅជាគម្រោងនៅឡើយ គណៈកម្មាធិការជាតិភាសាខ្មែរត្រូវបាន សម្តេចអគ្គមហាសេនាបតីតេជោ ជាប្រមុខរាជរដ្ឋាភិបាលបន្ថែមភារកិច្ចឲ្យត្រួតពិនិត្យការប្រើភាសានិងអក្សរខ្មែរក្នុងការបោះពុម្ពផ្សាយនិងបោះពុម្ពលើរូបសញ្ញាផ្សេងៗផងទៀត។

អាស្រ័យហេតុនេះ គម្រោងអនុក្រឹត្យស្តីពីការប្រើភាសានិងអក្សរខ្មែរក៏ត្រូវបានគ្រោងឡើងតាមការចង្អុលបង្ហាញពីឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី។ ប៉ុន្តែដោយគម្រោងអនុក្រឹត្យនេះ មានការពាក់ព័ន្ធជាមួយក្រសួងជាច្រើន គម្រោងនេះក៏ត្រូវបានអនុញ្ញាតឲ្យឆ្លងកិច្ចប្រជុំតាមនីតិវិធីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រោយពីបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេស សេចក្តីព្រាងអនុក្រឹត្យនេះក៏បានដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង[១]។

[១] អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ការប្រើភាសានិងអក្សរខ្មែរនៅលើរូបសញ្ញា។

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅរបស់ គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវលំ

កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ឡាំ ជា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវលំ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអភិវឌ្ឍន៍ជនបទ។



ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយាន្តយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវលំ ក្នុងគោលបំណងសំខាន់ គឺបង្កើតយន្តការ ដើម្បីដឹកនាំនិងត្រួតពិនិត្យយាន្តយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ដែលធ្វើចរាចរណ៍នៅលើផ្លូវលំនៃព្រះរាជាណាចក្រកម្ពុជា។

ដោយពិនិត្យឃើញថា បច្ចុប្បន្នសេដ្ឋកិច្ចនៅតំបន់ជនបទមានការរីកចម្រើន ដែលធ្វើឲ្យកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅជនបទក៏មានការប្រែប្រួលច្រើន ដែលធ្វើឲ្យសកម្មភាពដឹកជញ្ជូនកសិផល និងទំនិញផ្សេងៗមានការកើនឡើង។ រថយន្តខ្លះផ្ទុកលើសទម្ងន់កម្រិតកំណត់ធ្វើចរាចរណ៍លើបណ្តាញផ្លូវជនបទ ដែលបណ្តាលឲ្យមានការខូចខាតផ្លូវជាច្រើនកន្លែង ដែលធ្វើឲ្យរាជរដ្ឋាភិបាលត្រូវចំណាយថវិកាជាច្រើនរៀងរាល់ឆ្នាំ ដើម្បីធ្វើការជួសជុលនិងថែទាំផ្លូវទាំងនោះ។

# កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល



កន្លងមករាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយាន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ដែលធ្វើចរាចរណ៍លើបណ្តាញផ្លូវនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលគ្រប់គ្រងដោយក្រសួងសាធារណការនិងដឹកជញ្ជូន។ អនុក្រឹត្យនេះអាចប្រើប្រាស់បានសម្រាប់តែផ្លូវជាតិ និងខេត្តតែប៉ុណ្ណោះ ចំណែកឯផ្លូវជនបទមិនអាចប្រើបានទេ។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវលំនឹងទប់ស្កាត់រាល់ការប៉ះពាល់ធ្ងន់ធ្ងរដល់បណ្តាញផ្លូវជនបទ ពីការប្រើប្រាស់រថយន្តធុនធ្ងន់ផ្ទុកលើសទម្ងន់កម្រិតកំណត់ ក៏ដូចជាការបញ្ចៀសគ្រោះថ្នាក់ចរាចរណ៍ដែលអាចកើតមានជាយថាហេតុ និងធានាឲ្យហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទអាចប្រើប្រាស់បានយូរអង្វែងទៅតាមកាលកំណត់នៃលក្ខខណ្ឌបច្ចេកទេសសាងសង់ និងអាចជួយសន្សំសំចៃថវិការបស់រាជរដ្ឋាភិបាល ក្នុងការជួសជុលនិងថែទាំផ្លូវ(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីពាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើបណ្តាញផ្លូវលំ។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមេសា ឆ្នាំ២០១៣



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមេសា ឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ដែលដឹកនាំដោយឯកឧត្តម **យឹម ឈុនឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមេសា ឆ្នាំ២០១៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់**កើនឡើង ០,៦%** ធៀបនឹងខែមុន និង**កើនឡើង ១%** ធៀបនឹងខែដូចគ្នាឆ្នាំមុន(រយៈពេល១២ខែ)។ ការកើនឡើងថ្លៃទំនិញប្រើប្រាស់ធៀបនឹងខែមុននេះជាចម្បងបណ្តាលមកពីក្រុមម្ហូបអាហារ ដែលមានការរួមចំណែក ៩៦% ទៅលើការឡើងថ្លៃសរុប។

| បើធៀបនឹងខែដូចគ្នាឆ្នាំមុនក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម | | |
|---|---|---|
| *ក្រុមទំនិញ៖* | *មុខទំនិញ៖* | |
| ម្ហូបអាហារ:+២,១% | អង្ករ:+១,៦% | ត្រីស្រស់:-0,៤% |
| សម្លៀកបំពាក់និងស្បែកជើង:+២,៣% | សាច់គោស្រស់:+១៨% | ឧស្ម័ន: -៨,៥% |
| ផ្ទះសំបែងទឹកអគ្គិសនីឧស្ម័ន:0% | សាច់មាន់ស្រស់:+៤,១% | ប្រេងសាំង:-៧,៨% |
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់:+២,៨% | បន្លែ:+៦,៧% | ប្រេងម៉ាស៊ូត:-៧,៤%។ |
| ការដឹកជញ្ជូន:-៤,៧% | | |
| ភោជនីយដ្ឋាន:+២,៥% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំងអស់ទេ(មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១១–២០១៣

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា<sup>P</sup> | មិថុនា<sup>P</sup> | កក្កដា<sup>P</sup> | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ១,៣% | ១,៤% | ២,៤% | | | | | | - |
| | ខែមុន | ០,៣% | ០,២% | -០,១% | ០,៦% | -០,៨% | ០,២% | ១,០ | | | | | | |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | ខែមុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០ | ១,១% | ០,២% | -០,២% | -០,២% | ០ | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |

P: តួលេខខែឧសភា មិថុនានិងកក្កដាឆ្នាំ២០១៣ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

ក្រាហ្វ ១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ២០១១ ២០១២ និង២០១៣ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




➡អត្រាប្តូរប្រាក់៖

| ប្រភេទ | អត្រាខែមេសា ២០១៣ | អត្រាខែមីនា ២០១៣ | អត្រាខែមេសា ២០១២ | ប្រភេទ | អត្រាខែមេសា ២០១៣ | អត្រាខែមិនា ២០១៣ | អត្រាខែមេសា ២០១២ |
|---|---|---|---|---|---|---|---|
| ៛/ដុល្លារ | ៤០០០៛/១$ | ៣៩៩៥៛/១$ | ៤០២៥៛/១$ | បាត/ដុល្លារ | ២៩,២៦បាត/១$ | ២៩,៣២បាត/១$ | ៣០,៧៣បាត/១$ |
| ៛/បាត | ១៣៧៛/១បាត | ១៣៦៛/១បាត | ១៣១៛/១បាត | ដុង/ដុល្លារ | ២០៩០៥ដុង/១$ | ២០៩២០ដុង/១$ | ២០៨៣០ដុង/១$ |
| ៛/ដុង | ០,១៩២៛/១ដុង | ០,១៩១៛/១ដុង | ០,១៩៣៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមេសា ឆ្នាំ២០១៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១.ចំណូលថវិកាជាតិ៖** អនុវត្តបាន ៩០២,៤ ពាន់លានរៀល(មធ្យមប្រចាំខែ ៦៩% នៃគម្រោង)ក្នុងនោះចំណូលចរន្ត ៨៩១,៩ ពាន់លានរៀល(មធ្យមប្រចាំខែ ៩៦% នៃគម្រោង)និងចំណូលមូលធន ១០,៥ ពាន់លានរៀល។

➢បើធៀបនឹងខែមុន**ចំណូលថវិកាជាតិ** កើនឡើង ៣៥% និងកើនឡើង ២២%*ធៀបនឹងខែដូចគ្នាឆ្នាំមុន*។ ក្នុងនោះ ចំណូលចរន្តកើនឡើង ៣៣% ធៀបនឹងខែមុននិងកើនឡើង ២១% *ធៀបនឹងខែដូចគ្នាឆ្នាំមុន*។

ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១២ និង ២០១៣ (ពាន់លានរៀល)



➢នៅក្នុងចំណូលចរន្តៈ

✓ចំណូលសារពើពន្ធមានចំនួន ៨១៤,៣ ពាន់លានរៀល កើនឡើង ៣៨% ធៀបនឹងខែមុន និងកើនឡើង ២១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន ៧៧,៦ ពាន់លានរៀល ថយចុះ ៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| **មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ** (ក្នុងវង់ក្រចកៈបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ** (ក្នុងវង់ក្រចកៈបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ:-៦% | (+១២%) | ➢ នេសាទ:+៨៥% | (+៦៨%) |
| ➢ ចំណូលពន្ធដារ: +៩៦% | (+៣៧%) | ➢រុក្ខាប្រមាញ់ : — | (+៥៨%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ:+២៣% | (+៣០%) | ➢ អាកាសចរណ៍ស៊ីវិល:-៩១% | (-៤៦%) |
| ✧ កាស៊ីណូ :+៧៧% | (+៦២%) | ➢ ផលទុនទេសចរណ៍:+០,៤% | (+២៥%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក :-៩៩% | (-៩៥%) | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍:+៣១៣% | (-៣៣%) |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ :-៥% | (+២១%) | ➢អាករស្នានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ):+៣៦% | +១៥% |

២.២. *ចំណាយថវិកាជាតិ៖* អនុវត្តបានចំនួន ៧០៣ ពាន់លានរៀល( *មធ្យមប្រចាំខែ ៤៥% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៦២០ ពាន់លានរៀល ( *មធ្យមប្រចាំខែ ៦៤% នៃគម្រោង*) និង**ចំណាយមូលធន**ចំនួន ៨៣ ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន*ចំណាយថវិកាជាតិកើនឡើង ១២% ប៉ុន្តែថយចុះ ៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តកើនឡើង ២១% ធៀបនឹងខែមុនប៉ុន្តែថយចុះ ១៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯចំណាយមូលធន ថយចុះ ៣០% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៩២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ *ថវិកាជាតិនៃខែមេសាមានអតិរេក ១៩៩ ពាន់លានរៀល ស្មើនឹង ៤៩,៩ លានដុល្លារ ស.រ.អា*។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមេសា ឆ្នាំ២០១៣ មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ $M_2$ មានចំនួន ៣១១៦៣ ពាន់លានរៀល កើនឡើង ២,២% ធៀបនឹងខែមុន និងកើនឡើង ២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ កំណើន $M_2$ ធៀបនឹងខែមុនបណ្តាលមកពីរូបិយវត្ថុក្រៅធនាគារកើនឡើង ៣% ប្រាក់បញ្ញើចរន្តកើនឡើង ៣៣% និងប្រាក់បញ្ញើជារូបិយបណ្ណកើនឡើង ១,៨%។

➢ ក្នុងខែនេះ ប្រាក់រៀលសរុប**នៅក្នុងនិងក្រៅធនាគារ**មានចំនួន ១៧,៣% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨២,៧%។

**ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុខែមេសា ឆ្នាំ២០១៣**



| សមាមាត្រចំនួនប្រាក់រៀល ក្នុងរូបិយវត្ថុ $M_2$ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,២% | ១៧,៣% | ១៧,០% | ១៧,៣% | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៧% | ១៣,៧% | ១៣,៩% | ១៤,០% | | | | | | | | |

**បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែមេសា២០១៣៖ ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន**




- ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ (ខែមេសា : មិនទាន់មានតួលេខ)
- *ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ* ក្នុងខែនេះមានចំនួន ១០១៤៩ ពាន់លានរៀល កើនឡើង ០,៦% ធៀបនឹងខែមុន និងកើនឡើង ២៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- *ការផ្តល់ឥណទាន៖*

| *ផ្តល់ដោយ* | *មេសា ២០១៣* | *មិនា ២០១៣* | *មេសា ២០១២* |
|---|---|---|---|
| ធនាគារពាណិជ្ជ(ពាន់លានរៀល) | ២៥៤៣៨ | ២៤៨០០ | ១៩៣១២ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | មិនទាន់មានតួលេខ | ៣៩៨៥ | ២៨៥៥ |

- *អត្រាការប្រាក់ប្រចាំឆ្នាំ*នៅធនាគាពាណិជ្ជនាខែមេសា៖

| *ប្រភេទអត្រាការប្រាក់* | *មេសា២០១៣* | *មិនា២០១៣* | *មេសា២០១២* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៥,៩០% | ៦,០៨% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៨០% | ១៣,២៥% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៤,៤៤% | ៤,៤៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១១,៧២% | ១៣,៧៤% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែមេសាឆ្នាំ២០១៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- **កសិកម្ម៖**
  - ✓ផលិតផលនេសាទមានចំនួន ៤២,០ ពាន់តោនកើនឡើង ៤% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- **ឧស្សាហកម្ម៖**
  - ✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣១៨ GWh កើនឡើង ២% ធៀបនឹងខែមុន និងកើនឡើង ២១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

⇨ក្នុងនោះវារីអគ្គិសនីមានចំនួន ១៦,២ GWh កើនឡើង ៦៦% ធៀបនឹងខែមុន និងកើនឡើង ៣៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ២៩៨ លានដុល្លារ ថយចុះ ២៩% ធៀបនឹងខែមុននិងថយចុះ ៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| *ប្រភេទ* | *ចំនួន—មេសា២០១៣* | *ចំនួន—មិនា២០១៣* | *ចំនួន—មេសា២០១២* |
|---|---|---|---|
| ▪ រោងចក្រថ្មីដែលបានចុះបញ្ជី | ១២ | ១០ | ២៧ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ៩៥៦ | ៩៤៤ | ៧៥៩ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៦ | ២៣ | ២៩ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៨ | ១២ | ៨ |

**សំណង់** (ការអនុញ្ញាត)៖

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១២៦ ពាន់ម² ថយចុះ ៦១% ធៀបនឹងខែមុន និងថយចុះ ៨៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ៣៥ លានដុល្លារ ថយចុះ ៦២% ធៀបនឹងខែមុននិង ថយចុះ ៨៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| *ប្រភេទ* | *ពាន់ម²—មេសា២០១៣* | *ពាន់ម²—មិនា២០១៣* | *ពាន់ម²—មេសា ២០១២* |
|---|---|---|---|
| ▪ លំនៅឋាន | ៥៥,៨ | ២០៤,៦ | ២៦៤,៣ |
| ▪ ឧស្សាហកម្ម | ៤១,៣ | ៣៥,៨ | ១៤៧,៥ |
| ... | | | |
| អនុញ្ញាតសរុប | ១២៦ | ៣២៦ | ៨០៣ |

✓ដូច្នេះសំណង់ដែលពេញនិយមនាខែនេះគឺលំនៅឋាន ៤៤% នៃផ្ទៃក្រឡាអនុញ្ញាតសរុបនិងឧស្សាហកម្ម ៣៣%។

**ការងារ៖**

| *ប្រភេទ* | *នាក់—មេសា ២០១៣* | *%Δ ធៀបនឹងខែមុន* | *%Δធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១ ៦២៦ | ៣០% | -៣០% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២ ២៦១ | -២៣% | ១២% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៨១៧ | -៥៥% | ១៩៤% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១ ៤៤៤ | ៣០% | -១៧% |

**វិនិយោគ៖**

✓គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)៖

| *ប្រភេទ* | *មេសា២០១៣* | *មិនា២០១៣* | *មេសា២០១២* |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២១៤ | ២០ | ១២០ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ០ | ៤១ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១០៨(១០) | ២០ (០) | ៦១ (២៧) |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១០៦ | ០ | ១៨ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១២ | ៥ | ១៤ |
| បង្កើតការងារ (ពាន់នាក់) | ៨ | ៨ | ១៧ |

**សេវាកម្ម និងទេសចរណ៍៖**

✓**ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន — មេសា ២០១៣ | ចំនួន—មិនា២០១៣ | ចំនួន—មេសា ២០១២ |
|---|---|---|---|
| ▪ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២២៨ | ២៣២ | ២៦៥ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ០ | ០ | ៨ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ១១៦ | ៩៣ | ១៩៧ |

✓ទំនិញឆ្លងកាត់កំពង់ផែ(សរុប ៥កំពង់ផែ) មានចំនួន ៥០៣ ពាន់តោន ថយចុះ ៧% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង ៣១% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:+៣% | (+២០%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-៧% | (+៤៦%) |
| ▪ កំពង់ផែកំពង់សោម:+៤០% | (+៤១%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៥% | (+១០%) |

↳ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៨ | -២៨% | -១៤% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | មិនទាន់មានតួលេខ | — | — |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | មិនទាន់មានតួលេខ | — | — |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៨២ | +២៧% | +១៦% |
| ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ៣២៧ | -១៤% | +១៨% |
| ✓ តាមផ្លូវអាកាស | ១៤៥ | -២៤% | +១៥% |
| ✓ តាមផ្លូវគោក និងទឹក | ១៨២ | -៤% | +២០% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមេសាមានចំនួន ២៦៣៩ ពាន់លានរៀល (ស្មើនឹង ៦៦០ លានដុល្លារ ស.រ.អា.)ថយចុះ ៣% ធៀបនឹងខែមុនប៉ុន្តែកើនឡើង ១៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -៥% | +៤% | រថយន្តសរុប (ព.ល.រ) | -៦% | +២៧% |
| ប្រេងម៉ាស៊ូត | +៨% | +៧% | រថយន្តសរុប (គ្រឿង) | +២% | +២១% |
| ឧស្ម័ន | -២៤% | +៨៨% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -១៥% | +៧៩% |
| អគ្គិសនីនាំចូល | +៤% | +៣៦% | ម៉ូតូ (គ្រឿង) | -២២% | -១០% |
| ដែកសំណង់ | -៣៣% | +២៨% | អង្ករ | +១៥៣% | +៧៦១៩% |
| ស៊ីម៉ង់ត៍ | -៣២% | ០ | ផ្លែឈើនិងបន្លែ | -៤% | +២% |
| គ្រឿងអេឡិចត្រូនិក | +១៦% | +៣៦% | ជីនិងថ្នាំកសិកម្ម | +៣% | +៣៤% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +២០% | +៣៣% |

➡ **ការនាំចេញ** ក្នុងខែមេសាឆ្នាំ២០១៣ មានចំនួន ១៦៩៦ ពាន់លានរៀល ស្មើនឹង ៤២៤ លានដុល្លារ ស.រ.អា. (៦៤% នៃការនាំចូល)ថយចុះ ២៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៤៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ មុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | -៩៨% | -៩% | ផលិតផលនេសាទ | -៤៩% | +១៩៨% |
| វាយនភណ្ឌនិងស្បែកជើង | -២៧% | +៣៥% | កៅស៊ូ | +៥៣% | +៧០% |
| អង្ករ | -៣១% | +១០១% | | | |

➡ក្នុងខែមេសានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៩៤៤ ពាន់លានរៀល ស្មើនឹង ២៣៦ លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមេសា ឆ្នាំ២០១៣នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់គោស្រស់ | +២% | +១៨% | បញ្ហាការផ្គត់ផ្គង់ |
| ២ | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | -៥៩% | -៩៥% | — |
| ៣ | ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ | 0 | -២៣% | ជាចំនួនប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ |
| ៤ | សំណង់អនុញ្ញាត | -៦១% | -៨៤% | ប្រៀបធៀប៤ខែដើមឆ្នាំ ២០១៣ និង២០១២ សំណង់អនុញ្ញាតថយចុះប្រហែល ៤៣% |
| ៥ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក. | +៣៥៩% | -២៣% | បើប្រៀបធៀប៤ខែដើមឆ្នាំ ២០១៣ និង២០១២ ទុនវិនិយោគនេះថយចុះប្រហែល៥០% |
| ៦ | ការនាំចូលអង្ករ | +១៥៣% | +៧៦១៩% | មានការនាំចេញបន្ត |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) សាច់គោបន្តឡើងថ្លៃគួរឲ្យចាប់អារម្មណ៍បំផុត - បើធៀបនឹងខែមេសាឆ្នាំមុន សាច់គោឡើងថ្លៃ ១៨% ជាអត្រាខ្ពស់ជាងគេក្នុងចំណោមទំនិញដទៃទៀត។

២) សមាជិកភាពរបស់កម្ពុជាក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននាឆ្នាំ ២០១៥ នឹងប៉ះពាល់យ៉ាងខ្លាំងដល់ចំណូលពន្ធគយ ដែលបច្ចុប្បន្នកម្ពុជាពឹងផ្អែកលើចំណូលនេះប្រហែល ៥០%។

៣) ក្នុងករណីខ្លះ ហាក់ដូចជាមានការលើកទឹកចិត្តខ្លាំងពេកដូចជា ការលើកលែងពន្ធ ពន្ធអាករជាបន្ទុករដ្ឋជាដើម។

៤) មានការថយចុះគួរឲ្យចាប់អារម្មណ៍នៃសំណង់អនុញ្ញាត និងទុនវិនិយោគអនុញ្ញាត ។

***សេចក្តីសន្និដ្ឋាន៖***

១) ការធ្លាក់ចុះនៃចំនួនគោចិញ្ចឹម គឺជាបញ្ហាគួរឲ្យយកចិត្តទុកដាក់បំផុត។ បច្ចុប្បន្នការចិញ្ចឹមគោជាលក្ខណៈគ្រួសារលែងដើរតួសំខាន់សម្រាប់ការផ្គត់ផ្គង់ទៀតទេ។ ដូច្នេះ ត្រូវតែមានការចិញ្ចឹមជាលក្ខណៈទ្រង់ទ្រាយធំ។

២) កម្ពុជា**គួរតែត្រៀមខ្លួនឲ្យបានល្អ ដើម្បីចូល**ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥។ ការត្រៀមនេះរួមមាន៖

- ការពិនិត្យឡើងវិញអំពីលទ្ធភាពកំណែទម្រង់ស៊ីជំរៅ**នៃប្រព័ន្ធពន្ធដារ** ដូចជាប្រសិទ្ធភាពនៃការប្រមូលពន្ធ (**ការិយាធិបតេយ្យ**) **មូលដ្ឋាន**ពន្ធ **និង**ការថ្លឹងថ្លែង**អំពី**របបពិត និងរបបម៉ៅការ ។
- សហគ្រាសធុនតូច និងមធ្យម ដែលនៅក្មេងខ្ចីនិងងាយរងគ្រោះរបស់កម្ពុជា គួរទទួលបានការគាំទ្រមួយចំនួនទាំង បច្ចេកទេស យុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ ដើម្បីធ្វើឲ្យប្រសើរជាងមុននូវដំណើរការផលិតកម្ម និងគុណភាពទំនិញ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៣

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៥/១៣<br>ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០២/០៥/១៣<br>ម៉ោង ១៦ : ០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ម៉ៅ សុផាត** និងឯកឧត្តម **ហេង គំសាន្ត** នៅបន្ទប់ ឯកឧត្តម ប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៨/០៥/១៣<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងសារាចរ និងគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាន នៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ ។<br>៣-គម្រោងវិនិយោគសាងសង់ខ្សែបញ្ជូនថាមពលអគ្គិសនីតង់ស្យុងខ្ពស់២៣០ គីឡូវ៉ុល កំពង់ចាម-ក្រចេះ។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៩/០៥/១៣<br>ម៉ោង ១៨:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងជាមួយឯកអគ្គរាជទូតសហគមន៍អឺរ៉ុប នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា។ |
| ៥ | ១០/០៥/១៣<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គការតុលាការ និងអង្គការអយ្យការ។<br>២-សេចក្តីព្រាងសារាចរ និងគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាន នៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ។<br>៤-គម្រោងវិនិយោគសាងសង់ខ្សែបញ្ជូនថាមពលអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល កំពង់ចាម-ក្រចេះ។<br>៥-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖ "ពិធីសារទី២ ឆ្នាំ១៩៩៩ នៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ"។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៣ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៦ | ១៣/០៥/១៣ ម៉ោង ១៦:៣០នាទី | ចូលរួមក្នុងព្រះរាជពិធីថ្វាយព្រះពរជ័យ ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅលើព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង។ |
| ៧ | ១៦/០៥/១៣ ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសចូលកាន់មុខតំណែង អភិបាល អភិបាលរង នៃគណៈអភិបាលខេត្ត និងអភិបាលក្រុង-ស្រុក នៃខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលប្រជុំមន្ទីរសុខាភិបាល ខេត្តតាកែវ។ |
| ៨ | ១៧/០៥/១៣ ម៉ោង ១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការដេញថ្លៃ ដើម្បីចរចាតម្លៃលើការងារបន្ថែម នៃការងារសាងសង់សំណង់ទ្វារទឹកធំនៅលើស្ទឹងសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ២០/០៥/១៣ ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយអ្នកវិនិយោគកូរ៉េ របស់ក្រុមហ៊ុន AMOLUXE Co., Ltd. នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ២១/០៥/១៣ ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើភាសា និងអក្សរខ្មែរនៅលើរូបសញ្ញា។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីប្រព័ន្ធវាយតម្លៃ ថ្លៃអចលនទ្រព្យ។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ២៣/០៥/១៣ ម៉ោង ០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក MENANTEAU CEO ក្រុមហ៊ុន SCA នៅបន្ទប់ឯកឧត្តម ប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ២៣/០៥/១៣ ម៉ោង ១៥:៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៣ | ២៧/០៥/១៣ ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបុណ្យសម្ពោធឆ្លងកុដិ សម្តេចព្រះមហាអរិយវង្ស **សៅរ៍ ចន្ទថុល្ល** ព្រះចៅអធិការវត្តលង្កាព្រះកុសុមារាម និងពុទ្ធាភិសេកព្រះពុទ្ធរូបចំនួន ១២,៦៤៩អង្គ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅវត្តលង្កាព្រះកុសុមារាម សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៣ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៤ | **២៧/០៥/១៣** ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **នៅ សុតាគ្រា** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃ ទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២៨/០៥/១៣** ម៉ោង ០៧:៤៥នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីសំណេះសំណាល និងបិទវគ្គបណ្តុះបណ្តាលស្តីពីតួនាទីភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរ ជំនាន់ទី១០ ដល់ទី១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅសាលមហោស្រពកោះពេជ្រ។ |
| ១៦ | **២៩/០៥/១៣** ម៉ោង ០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសជាផ្លូវការនូវការប្តេជ្ញាចិត្តអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការរបស់អង្គការសហប្រជាជាតិ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រ **អ៉ីនឈាន់** "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" និងការបន្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០១៤-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៧ | **២៩/០៥/១៣** ម៉ោង ១៥:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និសីទវិទ្យាស្ថានខុងជឺ ក្នុងទ្វីបអាស៊ី ប្រចាំឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៨ | **៣០/០៥/១៣** ម៉ោង ០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | **៣០/០៥/១៣** ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក OLIVIER FLURY Area Manager Asia and America នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៣

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៥/១៣<br>ម៉ោង ១៦:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ម៉ៅ សុផាត** និង ឯកឧត្តម **ហេង តំសាន្ត** ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៦/០៥/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសចូលកាន់មុខតំណែង អភិបាល អភិបាលរង នៃគណៈអភិបាលខេត្តតាកែវ និងអភិបាលក្រុង-ស្រុក នៃខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តតាកែវ។ |
| ៣ | ២០/០៥/១៣<br>ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយអ្នកវិនិយោគកូរ៉េ របស់ក្រុមហ៊ុន AMOLUXE Co., Ltd ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២៣/០៥/១៣<br>ម៉ោង ១៦:៣០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសា និងអក្សរខ្មែរនៅលើរូបសញ្ញា។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពី ប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## ឯកឧត្តម ឌុយ ឌៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៥/១៣<br>ម៉ោង ១៦:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ម៉ៅ សុផាត** និង ឯកឧត្តម **ហេង តំសាន្ត** ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៦/០៥/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសចូលកាន់មុខតំណែង អភិបាល អភិបាលរង នៃគណៈអភិបាលខេត្តតាកែវ និងអភិបាលក្រុង-ស្រុក នៃខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តតាកែវ។ |
| ៣ | ២៣/០៥/១៣<br>ម៉ោង ១៦:៣០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសា និងអក្សរខ្មែរនៅលើរូបសញ្ញា។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពី ប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៣

## ឯកឧត្តម ម៉ាន់ តិរុណា អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/០៥/១៣<br>ម៉ោង ១៦:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ម៉ៅ សុផាត** និង ឯកឧត្តម **ហេង កំសាន្ត** ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១៦/០៥/១៣<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសចូលកាន់មុខតំណែង អភិបាល អភិបាលរង នៃគណៈអភិបាលខេត្តតាកែវ និងអភិបាលក្រុង-ស្រុក នៃខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តតាកែវ។ |
| ៣ | ២៣/០៥/១៣<br>ម៉ោង ១៦:៣០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រើប្រាស់ភាសា និងអក្សរខ្មែរនៅលើរូបសញ្ញា។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពី ប្រព័ន្ធវាយតម្លៃថ្លៃអចលនទ្រព្យ។<br>៣-សេចក្តីព្រាងគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។<br>៤-បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ក្នុងពិធីផ្សព្វផ្សាយគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

កាលពីថ្ងៃពុធទី៥ ខែមិថុនា ឆ្នាំ២០១៣ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ECOSOCC ជាអធិបតីភាព ក្នុងអង្គសិក្ខាសាលាស្តីពីពិធីផ្សព្វផ្សាយគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលរៀបចំដោយក្រុមការងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **យឹម ណុលសន** អនុប្រធាន ECOSOCC និងជានាយកគម្រោង RIA ឯកឧត្តម អនុប្រធាន សមាជិក អគ្គលេខាធិការ អគ្គលេខាធិការរង នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ លោកបណ្ឌិត Kelly Bird ឧត្តមសេដ្ឋវិទូនៃធនាគារអភិវឌ្ឍន៍អាស៊ី និងជាអ្នកគ្រប់គ្រងគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត តំណាងធនាគារអភិវឌ្ឍន៍អាស៊ី ឯកឧត្តម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងអស់លោក លោកស្រី មកពីក្រសួង-ស្ថាប័នមួយចំនួន។




ក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ណុលឡា** បានមានប្រសាសន៍ថា៖ ខ្ញុំសូមសម្តែងអំណរគុណដ៏ជ្រៀលជ្រៅបំផុតចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានយល់ព្រមឲ្យបង្កើតគម្រោង RIA នេះឡើង ដើម្បីអនុវត្តវិធីសាស្ត្រនៃការវិភាគលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ក្នុងការរៀបចំសំណើរបញ្ញត្តិកម្ម នៅទីស្តីការគណៈរដ្ឋមន្ត្រី។ នេះជា

OECD (អង្គការសម្រាប់សហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច) បានអនុវត្ត RIA ក្នុងទម្រង់ផ្សេងៗគ្នា។ នៅក្នុងតំបន់អាស៊ាន ប្រទេសវៀតណាម តម្រូវឲ្យអនុវត្ត RIA ដោយបានចែងនៅក្នុងច្បាប់ (ក្រិត្យលេខ ២៤/២០០៩/ NĐ-CP)។ ហើយប្រទេសដទៃទៀត ដូចជាប្រទេសឡាវ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងថៃ កំពុងតែធ្វើការពិសោធអនុវត្ត RIA ដូចកម្ពុជាដែរ។ សំខាន់ជាងនេះទៅទៀត អាស៊ានបានចេញគោលការណ៍ណែនាំស្តីពី RIA ហើយប្រទេសកម្ពុជាក៏បានយកគំរូដូចគ្នានេះដែរ។ ទៅអនាគត អាស៊ាននឹងតម្រូវឲ្យការរៀបចំគ្រប់លិខិតបទដ្ឋានគតិយុត្តដោយអនុវត្តតាមនិតិវិធី RIA។

ម្យ៉ាងវិញទៀត រនាំងពាណិជ្ជកម្មរបស់សហគមន៍អាស៊ាន នឹងត្រូវកាត់បន្ថយជាអតិបរិមា ក្នុងឆ្នាំ ២០១៥ ហើយពេលនោះទំនិញនិងសេវាកម្មអាចហូរឆ្លងប្រទេសនីមួយៗដោយសេរី។ ការអនុវត្ត RIA នឹងជួយឲ្យប្រទេសកម្ពុជាសម្របខ្លួនក្នុងការវិវឌ្ឍនេះ។ លទ្ធផលដែលបានមកពី RIA នឹងស្របតាមគោលដៅយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី២ នៃរាជរដ្ឋាភិបាលកម្ពុជា គឺកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធភាព ក្រោមការដឹកនាំដ៏ឆ្លៀសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំមានជំនឿថា រាជរដ្ឋាភិបាលកម្ពុជានឹងទទួលអត្ថប្រយោជន៍យ៉ាងច្រើនពីគម្រោង RIA នេះ ហើយការអនុវត្ត RIA ប្រទេសកម្ពុជានឹងអាចកាត់បន្ថយបានច្រើននូវការចំណាយកាតព្វកិច្ច។

ខ្ញុំមានសេចក្តីរីករាយ ដោយបានកត់សម្គាល់ឃើញថាមានវឌ្ឍនភាពជាច្រើនដែលបានសម្រេចនៅក្នុងរយៈពេលនៃការអនុវត្តគម្រោង RIA នៅប្រទេសកម្ពុជា។ យោងតាមវឌ្ឍនភាពនេះ ខ្ញុំគិតថា ជាពេលវេលាដ៏សមស្របដើម្បីផ្សព្វផ្សាយពីសមិទ្ធិកម្មនៃគម្រោង RIA នេះ។

ខ្ញុំយល់ថា ដើម្បីពង្រីកវិសាលភាពនៃការអនុត្ត RIA យើងគួរពង្រីកគម្រោងនេះដោយបញ្ចូលក្រសួងបន្ថែមទៀត។ ខ្ញុំយល់ថា RIA នេះជាឧបករណ៍ល្អមួយ និងជាការប្រតិបត្តិទម្លាប់ល្អ សម្រាប់ការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត ហើយនៅក្នុងរយៈពេលវែង RIA នេះនឹងត្រូវអនុវត្តនៅទូទាំងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

ខ្ញុំសង្ឃឹមថាបទបង្ហាញដ៏មានសារសំខាន់ពោរពេញដោយពត៌មានដែលនឹងត្រូវធ្វើក្នុងពេលបន្តិចទៀតដោយ ឯកឧត្តម អ្នកជំនាញជាតិ និងអន្តរជាតិ នឹងទទួលបានការចាប់អារម្មណ៍ច្រើន។ ខ្ញុំសូមអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី ចូលរួមផ្តល់មតិយោបល់ស្ថាបនា ដើម្បីឲ្យសិក្ខាសាលានេះទទួលបានផ្លែផ្កាល្អប្រសើរ។

ជាទីបញ្ចប់ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាភ្ញៀវជាតិ អន្តរជាតិ បានទទួលជោគជ័យក្នុងភារកិច្ចរៀងខ្លួន មានសុខភាពល្អ និងសុភមង្គលក្នុងគ្រួសារ។

# ព្រឹត្តិបត្រព័ត៌មាន


| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ខ៉ាន់ តិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង រត្នមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ធារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត ភក្កដា | មន្ត្រី ក.ស.វ. |




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in